**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សូមគោរពជូន

## សម្តេច អគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេច ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត** !

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចអគ្គមហាពញាចក្រី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាទទួលបានពានរង្វាន់ សន្តិភាព និងការអភិវឌ្ឍ ពីសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ាន (UMA) នាថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយ ឥតឧបមា និងអបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះ **សម្តេចអគ្គមហាពញាចក្រី** ដែលទទួលបាននូវពានរង្វាន់ ដ៏វិសេសវិសាលថ្លៃថ្លានេះ គឺជាការផ្តល់នូវមហាកិត្តិយស ដ៏ឧត្តុង្គឧត្តម សម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល ជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះស្នាដៃរបស់ **សម្តេច** ក្នុងនាមជាថ្នាក់ដឹកនាំប្រទេសជាតិដ៏ឆ្នើម ជាពិសេសនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា ការពារនិងរក្សាបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ប្រទេសជាតិ លើគ្រប់វិស័យ ។

សក្ខីភាពទាំងនេះ សរបញ្ជាក់អោយឃើញថា **សម្តេច** គឺជាថ្នាក់ដឹកនាំប្រកបដោយគតិបណ្ឌិត ក្នុងការកសាងនីតិរដ្ឋ ដើម្បីសន្តិភាពនិងការអភិវឌ្ឍ ហើយពានរង្វាន់នេះគឺពិតជាស័ក្តិសម ចំពោះពលិកម្មដ៏ថ្លៃថ្លា របស់ **សម្តេច** ដែលជានិច្ចកាល **សម្តេច** បានបូជាកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីដើម្បីបម្រើឧត្តមប្រយោជន៍ជាតិមាតុភូមិនិងប្រជាពលរដ្ឋ ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរនិងគោរពជូនពរ ចំពោះ **សម្តេច** ព្រមទាំងក្រុមគ្រួសារទាំងអស់ សូមមានសុខភាពល្អ បរិបូរណ៌ ជន្មាយុយឺនយូរ បញ្ញាញាណ ភ្លឺថ្លា ត្រចះត្រចង់ ដើម្បីបន្តដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសុខសន្តិភាព វឌ្ឍនភាព និងវិបុលភាពតរៀងទៅ។

សូម **សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមីនាឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ Generalsec@mod.gov.kh